**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# លិខិតសូមគោរពជូនពរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងឱកាសទទួលគ្រឿងឥស្សរិយយស "មិត្តភាព នៃសហព័ន្ធរុស្ស៊ី"

**សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

នៅក្នុងឱកាសដ៏មហាឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា ប្រកបដោយក្តីសោមនស្សរីករាយ មានអត្ថន័យដ៏ជ្រាលជ្រៅជាប្រវត្តិសាស្ត្រជាតិ ដែលឯកឧត្តម វ្លាឌីមៀរ ពូទីន "Vladimir Putin" ប្រធានាធិបតី នៃសហព័ន្ធរុស្ស៊ី ប្រគល់គ្រឿងឥស្សរិយយស **"មិត្តភាព នៃសហព័ន្ធរុស្ស៊ី"** ដែលជាគ្រឿងឥស្សរិយយសកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត សម្រាប់ថ្នាក់ដឹកនាំបរទេសជូនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ការទទួលបានគ្រឿងឥស្សរិយយស **"មិត្តភាព នៃសហព័ន្ធរុស្ស៊ី"** នេះ ជាមហាកិត្តិយសដ៏ឧត្តុង្គឧត្តមខ្ពង់ខ្ពស់បំផុត សម្រាប់ប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា និងបានបង្ហាញពីភាពទំនាក់ទំនងមិត្តភាពដ៏ជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរលើវិស័យនានា ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការជឿទុកចិត្ត និងការគាំទ្រគ្នាទៅវិញទៅមក មានតម្លៃ និងផលប្រយោជន៍រួមសំដៅលើកកម្ពស់ភាពជាដៃគូ ដើម្បីសន្តិភាព និងវិបុលភាព បានរីតតែខ្ពស់ថែមទៀត ជាគុណប្រយោជន៍នៃប្រទេស និងប្រជាជនរបស់យើងទាំងពីរ កម្ពុជា-រុស្ស៊ី។

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមបួងសួងដល់គុណបុណ្យព្រះរតនៈត្រ័យ វត្ថុស័ក្តសិទ្ធិក្នុងលោក និងទេវតាតាមជួយបីបាច់ថែរក្សាប្រទានពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរ គ្រប់ប្រការជូនចំពោះ **សម្តេចតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រាបុត្រី ចៅប្រុសចៅស្រី ជាទីស្រលាញ់ សូមបានប្រកបដោយពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងស្មោះស្ម័គ្របំផុតអំពីខ្ញុំបាទ ។

ថ្ងៃអង្គារ ៣រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**